# មាតង្គារញ្ញវត្ថុ

(រឿងព្រៃមាតង្គៈ)



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា


រៀបរៀងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ

**ភុល ផេង**


**ព.ស. ២៥៦៣**

# មាតង្គារញ្ញវត្ថុ

(រឿងព្រៃមាតង្គ)


*រៀបរៀងដោយ*

*បណ្ឌិត* **ភុល ផេង**


សីល សមាធិ បញ្ញា


**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៣**

# មាតង្គារញ្ញវត្ថុ

## (រឿងព្រៃមាតង្គៈ)

*ក្នុងអតីតកាល នៅក្នុងនគរពារាណសីមានស្ត្រីម្នាក់ ឈ្មោះ* ***ទិដ្ឋមង្គលិកា*** *ជាធីតារបស់សេដ្ឋីដែលមានទ្រព្យសម្បត្តិ ៨០ កោដិ នាងមានរូបស្អាត គួរឲ្យចង់ទស្សនា ជាស្រីនាំមកនូវសេចក្តីជ្រះថ្លា ។ នាងជាទីប្រាថ្នារបស់បុរសទាំងឡាយ ព្រោះនាងប្រកបព្រមដោយរូបសម្បត្តិ ភោគសម្បត្តិ និងកុលសម្បត្តិ។ អ្នកណាបញ្ជូនមនុស្សទៅកាន់សំណាក់នាង នាងគ្រាន់តែឃើញមនុស្សនោះភ្លាម នាងលើកទោសក្នុងរឿងជាតិមិនដូច្នោះក៏រឿងដៃជើងជាដើម យ៉ាងណាមួយឡើងហើយតិះដៀលថា អ្នកណានេះមានកំណើតមិនល្អ (ទ្រង់ទ្រាយមិនល្អ) ដូច្នេះជាដើម ហើយក៏បង្គាប់ឲ្យ*

ដេញគេត្រឡប់ទៅវិញ រួចពោលថា ខ្ញុំបានឃើញមនុស្សបែបនេះ ពួកអ្នកចូរយកទឹកមក ខ្ញុំនឹងលាងភ្នែក រួចហើយនាងក៏បានលាងភ្នែក ។ ព្រោះហេតុដែលនាងមានអាការៈ (ទិដ្ឋិ)ខុសប្រក្រតីពីអ្នកដទៃយ៉ាងនេះ ទើបប្រាកដឈ្មោះថា **ទិដ្ឋមង្គលិកា** ឈ្មោះដើមអំពីកំណើតរបស់នាងក៏បាត់ទៅ ។

ថ្ងៃមួយ នាងតាំងចិត្តថានឹងទៅលេងទឹកក្នុងទន្លេគង្គា បានបង្គាប់ឲ្យចាត់ចែងរៀបចំកំពង់ទឹក ដាក់ខាទនីយភោជនីយៈជាច្រើនពេញរទេះ យករបស់ក្រអូប និងផ្កាឈើជាដើម ឡើងជិះលើយានដែលបិទជិត មានពួកញាតិហែហមចេញចាកគេហដ្ឋានទៅ ។ ពេលនោះ ព្រះមហាបុរស (ជាពុទ្ធង្កូរបណ្ដាលពោធិសត្វនៃយើង) កើតក្នុងកំណើតចណ្ឌាល

អាស្រ័យនៅក្នុងផ្ទះដែលប្រក់ដោយស្បែក នៅខាង ក្រៅនគរ លោកមានឈ្មោះថា **មាតង្គៈ** មានអាយុ ១៦ ឆ្នាំ ត្រូវការចូលទៅក្នុងព្រះនគរ ដោយករណីយ-កិច្ចយ៉ាងណាមួយ ទើបស្លៀកសំពត់ចាស់ពណ៌ខៀវ មួយផ្ទាំង ចងកដៃមួយផ្ទាំង, ដៃម្ខាងកាន់កញ្ច្រែង ដៃម្ខាងទៀតកាន់កណ្តឹង (ធ្វើជាសញ្ញា) ដើម្បីឲ្យមនុស្សទាំងឡាយស្គាល់ខ្លួនថា "អស់អ្នកផងទាំងឡាយអើយ ខ្ញុំជាចណ្ឌាល" ដាក់ខ្លួន ឱនសំពះមនុស្សទាំងឡាយ ដែលខ្លួនជួប ដើរចូលទៅកាន់ព្រះនគរតាមមហាវិថីមួយ ។

នាងទិដ្ឋមង្គលិកាឮសំឡេងកណ្តឹង ក៏មើល តាមចន្លោះវាំងននឃើញនាយមាតង្គៈដែលកំពុងដើរ មកពីចម្ងាយ ក៏សួរអ្នកបម្រើថា គេនោះជាអ្វី ? ពួក

អ្នកបម្រើឆ្លើយថា អ្នកនាងម្ចាស់ គេគឺនាយមាតង្គៈ ។ នាងនិយាយថា ខ្ញុំបានធ្វើអកុសលទុកមកឬ ឬនេះជាផលកម្មអ្វី សេចក្ដីវិនាសទើបប្រាកដដល់ខ្ញុំ ដែលកំពុងទៅដោយកិច្ចដែលជាមង្គល ត្រឡប់បានជួបមនុស្សចណ្ឌាលទៅវិញ ។ នាងខ្ពើមឆ្អើមដរាបដល់ញ័រខ្លួនស្ដោះទឹកមាត់ ហើយប្រាប់ស្រីបម្រើថា នាងចូរប្រញាប់នាំទឹកមក យើងនឹងលាងភ្នែកដែលបានឃើញមនុស្សចណ្ឌាល ខ្ពុរមាត់ដែលនិយាយដល់ឈ្មោះមនុស្សចណ្ឌាល ហើយក៏លាងភ្នែកនិងមាត់ រួចឲ្យអ្នកបម្រើត្រឡប់រថ បញ្ជូនវត្ថុដែលត្រៀមទុក ទៅកាន់គេហដ្ឋាន ខ្លួនឯងក៏ឡើងទៅកាន់ប្រាសាទ ។

ពួកអ្នកលេងសុរាជាដើម និងពួកអ្នកបម្រើនាងកាលសួរថា "អ្នកនាងម្ចាស់ទិដ្ឋមង្គលិកាដ៏ចម្រើននៅ

ឯណា វេលានេះហើយ ហេតុអ្វីបានជាមិនទៅ" ? ពួកគេស្តាប់ដំណឹងនោះហើយ ក៏ចងគំនុំថា "ដោយសារមនុស្សបណ្ឌាលនេះ ពួកយើងទើបមិនបានទទួលរង្វាន់ធំដូចសុរាសាច់ របស់ក្រអូប កម្រងផ្កាឈើជាដើម ពួកអ្នកចូរនាំគ្នាចាប់មនុស្សបណ្ឌាលនេះ" ថាហើយស្វែងរកដរាបដល់ជួប រួចក៏សម្មតគំរាមមាតង្គ-បណ្ឌិត ដែលមិនមានកំហុសថា យើ! មាតង្គៈចង្រៃព្រោះអាស្រ័យអ្នក ពួកយើងទើបមិនបានរង្វាន់យ៉ាងនេះៗ ថាហើយក៏ចាប់សក់ទាញកន្ត្រាក់ដួលលើផែនដីវាយដំដោយដៃនិងដុំថ្មជាដើម ដរាបដល់មាតង្គៈសន្លប់, ពួកគេសម្គាល់ថា មាតង្គៈស្លាប់ ទើបនាំគ្នាចាប់អូសយកទៅចោលលើគំនរសំរាម ។

មហាបុរសដឹងខ្លួនឡើង ស្ទាបអង្អែលដៃជើង រួចគិតថា "ទុក្ខនេះកើតឡើងព្រោះអ្នកណាហ្ន៎" ដឹងថា "មិនមែនអ្នកដទៃណាមួយឡើយ គឺកើតឡើងព្រោះនាងទិដ្ឋមង្គលិកា" រួចហើយលោកពោលថា "ប្រសិនបើយើងជាបុរសពិត យើងនឹងឲ្យនាងទិដ្ឋមង្គលិកាទ្រោមចុះទៀបជើងឲ្យបាន" ជាអ្នកមានសេចក្ដីញាប់ញ័រខ្លាំងទៅកាន់ទ្វារផ្ទះរបស់នាងទិដ្ឋមង្គលិកា ដេកត្រង់លានផ្ទះដោយតាំងចិត្តថា "យើងបាននាងទិដ្ឋ-មង្គលិកា ទើបក្រោក បើមិនបានទេនឹងដេកស្លាប់ត្រង់ទីនេះឯង" ។ សម័យនោះ ក្នុងជម្ពូទ្វីបមានប្រពៃណី (បែបជំនឿ)ថា បើមនុស្សចណ្ឌាលក្រោធហើយដេកស្លាប់ជិតទ្វារបន្ទប់របស់អ្នកណា អ្នកដែលនៅក្នុងបន្ទប់នោះទាំងអស់ នឹងត្រូវក្លាយជាចណ្ឌាល, បើមនុស្សចណ្ឌាល ស្លាប់ត្រង់កណ្ដាលផ្ទះ អ្នកដែលនៅ

ក្នុងផ្ទះទាំងអស់ នឹងក្លាយជាចណ្ឌាល, បើមនុស្ស
ចណ្ឌាលស្លាប់ត្រង់ទ្វារ (ផ្ទះ) មនុស្សទាំងពីរចំណែក
គឺនៅក្នុងផ្ទះ និងនៅក្នុងបន្ទប់ នឹងត្រូវក្លាយជា
ចណ្ឌាល, បើមនុស្សចណ្ឌាលស្លាប់ត្រង់ទីលានផ្ទះ
វិញ មនុស្សដែលនៅក្នុងផ្ទះទាំង ១៤ ខ្នង គឺអំពីខាង
នេះ ៧ ខាងនោះ ៧ ត្រូវក្លាយជាចណ្ឌាលទាំងអស់ ។
ចំណែកព្រះពោធិសត្វដេកត្រង់ទីលានផ្ទះ ។

មនុស្សទាំងឡាយប្រាប់សេដ្ឋីថា លោកម្ចាស់
នាយមាតង្គៈដេកត្រង់ទីលានផ្ទះរបស់លោក ។ សេដ្ឋី
និយាយថា ពួកអ្នកចូរទៅហើយពោលថា ព្រោះហេតុ
អ្វី (បានជាអ្នកមកដេកនៅទីនេះ) រួចឲ្យទ្រព្យវាមួយ
មាសកៈ និងឲ្យវាក្រោកចេញទៅ ។ មនុស្សទាំងនោះ
ទៅប្រាប់ថា នែមាតង្គៈ ចូរក្រោកឡើង យកមាសកៈ

ហើយទៅចុះ ។ នាយមាតង្គៈពោលថា ខ្ញុំដេកមិនមែន ដើម្បីត្រូវការមាសកៈទេ ខ្ញុំដេកដើម្បីចង់បាននាងទិដ្ឋ-មង្គលិកា។ មនុស្សទាំងឡាយសួរថា នាងទិដ្ឋមង្គលិកា មានទោសអ្វីឬ?។ មាតង្គៈឆ្លើយថា ពួកអ្នកឯង មើល មិនឃើញទោសអ្វីៗរបស់នាងទេឬ ខ្ញុំមិនមានកំហុស សោះ ត្រូវពួកមនុស្សរបស់នាងធ្វើខ្ញុំឲ្យឈឺចាប់គ្រាំគ្រា កាលខ្ញុំបាននាងទើបខ្ញុំក្រោក កាលមិនបាន ខ្ញុំនឹងមិន ក្រោកឡើយ ។

មនុស្សទាំងនោះទៅប្រាប់សេដ្ឋី។ សេដ្ឋីដឹង ទោសរបស់ធីតាហើយ ទើបបញ្ជូនមនុស្សទៅ ព្រម ទាំងប្រាប់ថា ពួកអ្នកចូរទៅ ហើយឲ្យវាមួយកហា-បណៈ ។ នាយមាតង្គៈពោលថា ខ្ញុំមិនប្រាថ្នាកហា-បណៈទេ ប្រាថ្នាតែនាងទិដ្ឋមង្គលិកាប៉ុណ្ណោះ ។ សេដ្ឋី

និងកិរិយាមានសេចក្ដីសង្វេគថា "ធីតាជាទីស្រឡាញ់តែម្នាក់របស់យើង ទម្លាយប្រពៃណីហើយ សូម្បីក្មេងដទៃក៏មិនមាន" ទើបប្រាប់អ្នកបម្រើថា "នែអ្នកទាំងឡាយ អ្នកណាមួយមិនអាចអត់ទ្រាំ គប្បីសម្លាប់ជីវិតធីតារបស់យើង កាលបើធីតារបស់យើងស្លាប់ហើយ យើងក៏នឹងវិនាសដែរ ពួកអ្នកចូររក្សាធីតាយើង" ថាហើយក៏ចាត់ចែងរក្សាធីតា រួចបញ្ជូនបបរបាយ ទ្រព្យទៅឲ្យព្រះពោធិសត្វ តែត្រូវព្រះពោធិសត្វបដិសេធគ្រប់យ៉ាង។ វេលាក៏កន្លងទៅថ្ងៃមួយ ពីរ បី បួន ប្រាំថ្ងៃ ។

មនុស្សដែលនៅផ្ទះទាំង ៧ ។ អំពីផ្ទះនោះក្រោកឡើងនិយាយថា ពួកយើងមិនអាចក្លាយជាចណ្ឌាល ព្រោះពួកលោកបានទេ ពួកលោកកុំធ្វើឲ្យ

យើងវិនាសឡើយ ចូរឲ្យនាងទិដ្ឋមង្គលិកា ហើយឲ្យ
មាតង្គៈក្រោកឡើង ។ សេដ្ឋីនិងភរិយានោះក៏បញ្ជូន
ទ្រព្យទៅឲ្យមាតង្គៈមួយរយខ្ទះ មួយពាន់ខ្ទះ មួយ
សែនខ្ទះ, នាយមាតង្គៈនៅតែបដិសេធដដែល ។
ប្រាំមួយថ្ងៃក៏កន្លងផុតទៅយ៉ាងនេះ ។ ដល់ថ្ងៃទី៧
មនុស្សដែលនៅក្នុងផ្ទះទាំង ១៤ អំពីខាងទាំងពីរ មក
ប្រជុំគ្នាថា យើងមិនអាចក្លាយជាចណ្ឌាលឡើយ
យើងនឹងឲ្យនាងទិដ្ឋមង្គលិកាដល់នាយមាតង្គៈ សូម្បី
ពួកលោកក៏មិនប្រាថ្នាក៏ដោយ។

មាតាបិតារបស់នាងទិដ្ឋមង្គលិកាពេញដោយ
សេចក្តីសោក ដកដង្ហើមដល់សន្ទប់ ដួលចុះលើទីដេក ។
មនុស្សដែលនៅក្នុងផ្ទះទាំង ១៤ អំពីខាងទាំងពីរ នាំ
គ្នាឡើងលើប្រាសាទ ដោះគ្រឿងប្រដាប់គ្រប់យ៉ាង

របស់នាងទិដ្ឋមង្គលិកា ដូចជាបេះមែកចារដែលមាន ផ្កាកំពុងរីក យកក្រចកវែកសក់ហើយចងទុក ឲ្យ ស្បៀកសំពត់ចាស់ៗពណ៌ខៀវ ចងកំណាត់សំពត់ខៀវ ចាស់ៗទុកត្រង់ដៃ ឲ្យប្រដាប់ក្រវិលសំណាត្រង់ត្រចៀក ទាំងសងខាង ប្រគល់កញ្ច្រែងស្មឹកត្នោត ឲ្យចុះអំពី ប្រាសាទ ចាប់ដៃទាំងពីរប្រគល់ឲ្យមហាបុរសព្រម ទាំងពោលថា នាងឯងចូរនាំស្វាមីរបស់នាងទៅចុះ ។

នាងទិដ្ឋមង្គលិកាជាក្មេងស្រីសុខុមាលជាតិ មិនធ្លាប់លើករបស់ធ្ងន់សូម្បីតែផ្កាឈូកខៀវ ក៏ និយាយនឹងមាតង្គៈថា ក្រោកឡើងមកនាយ យើងទៅ ជាមួយគ្នា ។ ព្រះពោធិសត្វនៅតែដេកដដែល និយាយថា យើងមិនក្រោកទេ ។ នាងសួរថា នឹងឲ្យខ្ញុំ និយាយដូចម្ដេច? ។ នាយមាតង្គៈពោលថា នាងចូរ

និយាយចំពោះយើងថា បពិត្រមាតង្គៈដ៏ចម្រើន សូមលោកក្រោកឡើង ។ នាងទិដ្ឋមង្គលិកាក៏ពោលយ៉ាងនោះ ។ នាយមាតង្គៈពោលថា ពួកមនុស្សរបស់នាងបានធ្វើឲ្យយើងមិនអាចក្រោកឡើង នាងចូរចាប់ដើមដៃរបស់យើង ជួយឲ្យយើងក្រោកឡើង ។ នាងក៏ធ្វើយ៉ាងនោះ ។ ព្រះពោធិសត្វបែខ្លួន ធ្វើជាឈរឡើង ក៏ដួលចុះទៅលើផែនដី ហើយស្រែកឡើងថា អ្នកទាំងឡាយអើយ កាលមុន នាងទិដ្ឋមង្គលិកាប្រើឲ្យមនុស្សទាំងឡាយឲ្យវាយខ្ញុំ ឥឡូវនេះនាងវាយខ្ញុំដោយខ្លួនឯងទៀត ។ នាងទិដ្ឋមង្គលិកានិយាយថា នឹងឲ្យខ្ញុំធ្វើយ៉ាងដូចម្តេច លោកម្ចាស់ ។ ព្រះពោធិសត្វ ពោលថា នាងចូរចាប់ដៃទាំងពីរលើកយើងឲ្យក្រោកឡើង ។ នាងទាញឲ្យងើបឡើង ដាក់ឲ្យអង្គុយ រួចនិយាយថា នែនាយ យើងនឹងទៅជាមួយ

គ្នា ។ ព្រះពោធិសត្វពោលថា ធម្មតា គុម្ពឈើ ឈើតូច តែងមាននៅក្នុងព្រៃ យើងជាមនុស្ស ត្រូវមនុស្សរបស់ នាងវាយយ៉ាងធ្ងន់ធ្ងរ មិនអាចដើរទៅដោយជើងបាន ទេ នាងចូរយកខ្នងលីយើងទៅ ។ នាងក៏បង្អោនខ្លួន ចុះ ប្រគល់ខ្នងឲ្យ, ព្រះពោធិសត្វក៏ឡើងជិះលើនាង។ នាងសួរថា ខ្ញុំនាំលោកទៅទីណា ? មាតង្គៈពោលថា ចូរនាងនាំយើងទៅខាងក្រៅនគរ ។ នាងទិដ្ឋមង្គលិកា នាំកាន់ទ្វារក្រុងទិសខាងកើត ហើយសួរទៀតថា ទី លំនៅរបស់លោកនៅទីនេះឬ ។ ព្រះពោធិសត្វសួរថា ដល់ណាហើយ ? នាងប្រាប់ថា ដល់ទ្វារក្រុងទិសខាង កើត ។ ព្រះពោធិសត្វពោលថា "ត្រង់ទ្វារក្រុងទិសខាង កើត កូនមនុស្សចណ្ឌាលនៅមិនបានទេ" លោកមិន ទាន់ប្រាប់លំនៅរបស់ខ្លួនតែម្តងទេ ឲ្យនាងទិដ្ឋ- មង្គលិកាលីខ្លួនទៅកាន់ទ្វារក្រុងគ្រប់ទិស ។

**សួរថា** ព្រោះហេតុអ្វី ?

**ឆ្លើយថា** ព្រះពោធិសត្វគិតថា យើងនឹងបំបាក់មានះរបស់នាងទិដ្ឋមង្គលិកាដែលឡើងដល់កម្រិតកំពូលនេះឲ្យបាន ។

មហាជនស្រែកហ៊ោយ៉ាងគឹកកងថា ក្រៅអំពីមនុស្សដូចលោក មិនមានអ្នកដទៃណាដែលអាចបំបាក់មានះរបស់នាងទិដ្ឋមង្គលិកានេះបានទេ ។

នាងទិដ្ឋមង្គលិកានាំព្រះពោធិសត្វទៅដល់ទ្វារក្រុងទិសខាងលិច ហើយក៏សួរថា តើលំនៅរបស់លោកនៅក្នុងទីនេះឬ ? ព្រះពោធិសត្វសួរថា ទីនេះជាកន្លែងអ្វី ? នាងឆ្លើយថា ទ្វារក្រុងទិសខាងលិច ។ មាតង្គពោធិសត្វពោលថា ចូរនាងចេញតាមទ្វារក្រុងនេះ កាលឃើញផ្ទះប្រក់ដោយស្បែក ចូរទៅតាមនោះ

ចុះ ។ នាងដើរទៅដល់ហើយក៏សួរថា ផ្ទះនេះជាទីនៅរបស់លោកឬ ? មាតង្គៈឆ្លើយថា បាទ ហើយក៏ចុះអំពីខ្នងនាង ដើរចូលទៅកាន់ផ្ទះដែលប្រក់ដោយស្បែកនោះ (យ៉ាងព្រងើយ) ។

ព្រះពោធិសត្វជាអ្នកប្រាជ្ញ ដែលស្វែងរកសព្វញ្ញុតញ្ញាណ នៅក្នុងផ្ទះនោះអស់ ៧-៨ ថ្ងៃ ក៏មិនបានធ្វើនូវ**ជាតិសម្ភេទ** (ការទម្លាយជាតិ) (គឺមិនបានរួមសង្វាសនាងទិដ្ឋមង្គលិកាឡើយ) ។ លោកគិតថា "បើធីតារបស់ត្រកូលដ៏ធំអាស្រ័យយើងហើយ មិនបានយសធំ យើងនឹងមិនមែនជាសិស្សរបស់ព្រះពុទ្ធដល់ទៅ ២៤ ព្រះអង្គឡើយ, យើងនឹងធ្វើកិច្ចអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប ដោយទឹកលាងជើងរបស់នាង" រួចលោកគិតទៀតថា បើយើងនៅក្នុង

ផ្ទះ (ជាគ្រហស្ថ) គង់មិនអាចធ្វើបានឡើយ បើយើង
បួសហើយ ទើបអាចធ្វើបាន ។ គិតរួចក៏ហៅនាងទិដ្ឋ-
មង្គលិកាមក ហើយប្រាប់ថា នែនាងទិដ្ឋមង្គលិកា ពី
មុនយើងនៅម្នាក់ឯង ធ្វើការងារខ្លះ ក៏ល្មមចិញ្ចឹមជីវិត
បាន តែឥឡូវនេះ យើងមានភរិយា បើមិនធ្វើការងារ
(ច្រើនទេ) មិនអាចនឹងរស់បានឡើយ នាងកុំអផ្សុក
ដរាបដល់យើងត្រឡប់មក ។ ព្រះពោធិសត្វចូលទៅ
ព្រៃ រើសយកសំពត់ប្រឡាក់ៗ ក្នុងព្រៃជាទីចោល
សាកសពជាដើម មកធ្វើសំពត់ស្លៀកដណ្តប់ បួសជា
សមណៈត្រាច់ទៅម្នាក់ឯង បានសេចក្តីស្ងាត់កាយ
បរិកម្មកសិណ ញ៉ាំងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យ
កើតឡើង ហើយគិតថា ឥឡូវនេះយើងអាចជាទីពឹង
របស់នាងទិដ្ឋមង្គលិកា ទើបដើរទៅ បែរមុខឆ្ពោះទៅ

កាន់ក្រុងពារាណសី ដណ្ដប់ចីវរ ត្រាច់ភិក្ខាចារ ដើរត្រង់ទៅកាន់ផ្ទះរបស់នាងទិដ្ឋមង្គលិកា ។

នាងទិដ្ឋមង្គលិកាឃើញព្រះពោធិសត្វឈរជិតទ្វារ ចាំមិនបាន ក៏ប្រាប់ថា មេត្តាលោកនិមន្តទៅខាងមុខចុះ នេះជាលំនៅរបស់មនុស្សចណ្ឌាល។ ព្រះពោធិសត្វក៏ឈរនៅទីនោះឯង។ នាងទិដ្ឋមង្គលិកាមើលហើយមើលទៀតក៏ចាំបាន យកដៃគក់ទ្រូងស្រែកយំ ដួលចុះជិតជើង ហើយពោលថា "បពិត្រស្វាមី បើអ្នកមានចិត្តបែបនេះ ហេតុអ្វីបានជាអ្នកធ្វើខ្ញុំឲ្យសាបសូន្យចាកយសធំ ធ្វើខ្ញុំឲ្យមិនមានទីពឹង" ហើយទួញយំរៀបរាប់ផ្សេងៗ ជូតភ្នែកពីរ ក្រោកឡើងទទួលភាជនៈអាហារ និមន្តព្រះពោធិសត្វឲ្យចូលទៅអង្គុយខាងក្នុងផ្ទះ រួចថ្វាយអាហារ ។ ព្រះមហាបុរស

ឆាន់ហើយ ក៏ពោលថា នែនាងទិដ្ឋមង្គលិកា នាងកុំសោកសៅ កុំទួញយំអី យើងអាចធ្វើកិច្ចគឺការអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប ដោយទឹកជម្រះជើងរបស់នាង តែនាងត្រូវធ្វើតាមពាក្យរបស់យើងមួយ ចូរនាងចូលទៅក្នុងនគរ ប្រកាសឲ្យទូទៅក្នុងនគរថា ស្វាមីរបស់ខ្ញុំមិនមែនចណ្ឌាលទេ លោកជាមហាព្រហ្ម ។

កាលព្រះពោធិសត្វពោលយ៉ាងនោះហើយ នាងទិដ្ឋមង្គលិកាក៏និយាយថា សូម្បីដោយប្រក្រតី ខ្ញុំក៏ដល់សេចក្តីវិនាសព្រោះទោសនៃមាត់ ខ្ញុំមិនអាចនិយាយបានទេ ។ ព្រះពោធិសត្វពោលថា "កាលយើងនៅក្នុងផ្ទះ នាងធ្លាប់ឮពាក្យសម្តីផ្តេសផ្តាសឬយើងមិននិយាយផ្តេសផ្តាសសូម្បីក្នុងគ្រានេះ ឥឡូវ

យើងបួសហើយ នឹងនិយាយផ្តេសផ្តាសបានយ៉ាងណា យើងឈ្មោះថាជាបុរសនិយាយតែពាក្យពិត ថ្ងៃនេះជាថ្ងៃ ៨ កើតនៃបក្ខ នាងចូរប្រកាសថា "ក្នុងថ្ងៃឧបោសថ កន្លងទៅ ៧ ថ្ងៃ រាប់ពីថ្ងៃនេះ មហាព្រហ្មជាស្វាមីរបស់ខ្ញុំ នឹងទម្លាយមណ្ឌលព្រះចន្ទ ហើយមកកាន់សម្នាក់ខ្ញុំ" នាងចូរប្រកាសទូទាំងសកលជម្ពូទ្វីបចុះ" ថារួចព្រះពោធិសត្វក៏ចៀសចេញទៅ ។

នាងទិដ្ឋមង្គលិកាជឿ មានចិត្តរីករាយត្រេកអរក្វាហានចូលទៅកាន់ព្រះនគរ ក្នុងវេលាព្រឹកល្ងាចប្រកាសយ៉ាងនោះ ។ មនុស្សទាំងឡាយក៏ទះដៃសើចចំអកឡកឡឺយថា អ្នកទាំងឡាយចូរមើលចុះ នាងទិដ្ឋមង្គលិការបស់យើង ធ្វើកូនចណ្ឌាលឲ្យជាមហា-ព្រហ្ម។ សូម្បីថ្ងៃស្អែក នាងក៏ចូលទៅក្នុងពេលព្រឹក

ល្ងាច ប្រកាសយ៉ាងនោះឯងថា ឥឡូវនេះ កន្លងទៅ ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃ ៦ ថ្ងៃ ឥឡូវនេះ មហាព្រហ្មជាស្វាមីរបស់ខ្ញុំនឹងទម្លាយមណ្ឌលព្រះចន្ទ មកកាន់សម្នាក់របស់ខ្ញុំ ។

ព្រាហ្មណ៍ទាំងឡាយគិតគ្នាថា នាងទិដ្ឋមង្គលិកានេះក្លាហានណាស់ នាងនិយាយយ៉ាងនេះពេលខ្លះអាចនឹងមានដូច្នោះដែរ មកចុះអ្នកទាំងឡាយ យើងនឹងចាត់ចែងទីនៅរបស់នាងទិដ្ឋមង្គលិកា ហើយជួយគ្នាបោសប្រាសសម្អាតទីជុំវិញខាងក្រៅផ្ទះដែលប្រក់ដោយស្បែក និងរោយខ្សាច់ទុកសូម្បីនាងទិដ្ឋមង្គលិកាក៏ចូលទៅកាន់ព្រះនគរអំពីព្រឹក ក្នុងថ្ងៃឧបោសថប្រកាសថា ថ្ងៃនេះ ស្វាមីរបស់ខ្ញុំនឹងមក ។ ព្រាហ្មណ៍ទាំងឡាយ គិតគ្នាថា នាងទិដ្ឋ-

មង្គលិកានេះអះអាងមិនឆ្ងាយឡើយ បានឮថា ថ្ងៃនេះមហាព្រហ្មនឹងមក ពួកយើងជួយគ្នាចាត់ចែងទីលំនៅ ហើយបោសសម្អាតផ្ទះដែលប្រក់ដោយស្បែកឲ្យស្អាត ធ្វើផ្ទៃដីឲ្យមានពណ៌ខៀវ ហុំព័ទ្ធដោយសំពត់ថ្មីៗ ក្រាលបល្ល័ង្កដែលសមគួរខ្នាតធំ រុំពិតានសំពត់ទុកខាងលើ ព្យួររបស់ក្រអូប និងកម្រងផ្កា។ កាលព្រាហ្មណ៍ទាំងនោះកំពុងចាត់ចែង ព្រះអាទិត្យក៏អស្តង្គតទៅ ។

កាលព្រះចន្ទរះឡើង ព្រះមហាបុរសក៏ចូលឈានដែលជាបាទរបស់អភិញ្ញា ចេញចាកអភិញ្ញាហើយ ធ្វើបរិកម្មដោយកាមាវចរចិត្ត និម្មិតអត្តភាពជាព្រហ្ម ប្រមាណ ១២ យោជន៍ ដោយចិត្តដែលប្រកបដោយឫទ្ធិ ហោះឡើងកាន់អាកាសវេហាស៍ ចូលទៅ

ក្នុងវិមានព្រះចន្ទ ទម្លាយវិមានព្រះចន្ទ ដែលកំពុងអណ្តែតឡើងអំពីទីបំផុតព្រៃ លះវិមានព្រះចន្ទ មកនៅខាងមុខ អធិដ្ឋានថា មហាជនចូរឃើញយើង។ មហាជនឃើញហើយ ក៏ពោលថា អ្នកដ៏ចម្រើនទាំងឡាយ ពាក្យរបស់នាងទិដ្ឋមង្គលិកាជាពាក្យពិត ស្តេចមហាព្រហ្មយាងមកមែន ពួកយើងនឹងបូជាលោក ថាហើយកាន់យករបស់ក្រអូប និងកម្រងផ្កាឈរលោមព័ទ្ធផ្ទះនាងទិដ្ឋមង្គលិកា ។ ព្រះមហាបុរសហោះវិលជុំវិញក្រុងពារាណសី ៧ ជុំ ដឹងថា មហាជនបានឃើញហើយ លះអត្តភាពប្រមាណ ១២ យោជន៍ ហើយនិម្មិតអត្តភាពប៉ុនមនុស្សធម្មតា កាលមហាជនកំពុងមើល ក៏ចូលកាន់ផ្ទះដែលប្រក់ដោយស្បែក ។ មហាជនឃើញហើយក៏និយាយថា ស្តេចមហាព្រហ្មរបស់ពួកយើងយាងចុះមកហើយ ពួកអ្នកចូរនាំ

វាំងននមក, រុំព័ទ្ធនិវេសន៍ទុកដោយវាំងននខ្នាតធំ ហើយឈរលោមព័ទ្ធ ។

ចំណែកព្រះមហាបុរសក៏អង្គុយនៅត្រង់កណ្ដាលទីដេកដ៏មានសិរី ។ នាងទិដ្ឋមង្គលិកាមកឈរជិត ។ គ្រានោះ ព្រះពោធិសត្វសួរនាងថា ម្នាលទិដ្ឋ-មង្គលិកា នាងមានរដូវហើយឬ ។ នាងឆ្លើយថា ចាស ។ ព្រះមហាបុរសពោលថា នាងចូរទទួលបុត្រ ដែលយើងប្រគល់ឲ្យចុះ ថាហើយលោកយកម្រាមដៃស្ទាបអង្អែលបរិវេណផ្ចិត ។ ដោយការស្ទាបអង្អែលផ្ចិតនោះនាងក៏តាំងគភ៌ ។ ព្រះមហាបុរសពោលថា ម្នាលទិដ្ឋ-មង្គលិកា ដោយហេតុត្រឹមប៉ុណ្ណេះ ទឹកលាងជើងរបស់នាង នឹងជាទឹកអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប នាងចូរងើបឡើង ដូច្នេះហើយ ព្រះ

ពោធិសត្វនិម្មិតអត្តភាពជាព្រហ្ម កាលមហាជនកំពុង
មើល លោកក៏ចេញពីផ្ទះ ហោះឡើងកាន់អាកាស
វេហាស៍ ចូលទៅកាន់មណ្ឌលព្រះចន្ទ ។ តាំងពីពេល
នោះមក នាងទិដ្ឋមង្គលិកា ក៏មានឈ្មោះថា
**ព្រហ្មបជាបតី** ។ ឈ្មោះថាមនុស្សដែលមិនបានទឹក
សម្រាប់លាងជើង រមែងមិនមាន ។

ពួកព្រាហ្មណ៍ប្រឹក្សាគ្នាថា ពួកយើងនឹង
អញ្ជើញព្រហ្មបជាបតីឲ្យចូលទៅនៅខាងក្នុងព្រះនគរ
រួចនាំគ្នាសែងដោយគ្រែស្នែងមាស មិនឲ្យអ្នកដែល
មានជាតិមិនបរិសុទ្ធិ ៧ តំណ សែងឡើយ ។
ព្រាហ្មណ៍អ្នកមានជាតិ ១៦ នាក់សែងទៅ ។ មនុស្សដ៏
សេសបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម ចូល
ទៅកាន់ព្រះនគរ ហើយប្រឹក្សាគ្នាថា នៃអ្នកដ៏ចម្រើន

ទាំងឡាយ ព្រហ្មបជាបតីមិនអាចនៅក្នុងផ្ទះដែលខ្លួនធ្លាប់នៅឡើយ ពួកយើងនឹងរកទីដីសាងផ្ទះដល់នាង នាងចូរទៅត្រង់មណ្ឌប ដរាបដល់ផ្ទះសាងរួច ដូច្នេះ ហើយចាត់ចែងឲ្យនាងនៅក្នុងមណ្ឌប ។ តាំងពីពេលនោះមក មនុស្សទាំងឡាយណាដែលឈរមើលល្មមឃើញនាង ប្រាថ្នាបង្គំនាង ត្រូវបង់ប្រាក់ ១ កហាបណៈ ទើបបានថ្វាយបង្គំនាង ។ អ្នកដែលឈរក្នុងទីដែលអាចស្តាប់ឮសំឡេងនាង (ឧបចារៈនៃការស្តាប់) ប្រាថ្នាបង្គំនាង ត្រូវបង់ប្រាក់ ១០០ កហាបណៈ ទើបបានថ្វាយបង្គំនាង ។ អ្នកដែលអង្គុយក្នុងទីជិត ដែលជាទីស្តាប់ឮសំឡេងនិយាយតាមប្រក្រតី ប្រាថ្នាបង្គំនាង ត្រូវបង់ប្រាក់ ៥០០ កហាបណៈ ទើបថ្វាយបង្គំនាង ។ អ្នកណាត្រូវការដាក់ក្បាលលើខ្នងជើងហើយថ្វាយបង្គំ ត្រូវបង់ ១០០០ កហាបណៈ ។ អ្នកណាប្រាថ្នាចង់បាន

ទឹកលាងជើង ត្រូវបង់មួយម៉ឺនកហាបណៈ ទើបបាន ទឹកនោះ ។ កាលដែលនាងធ្វើដំណើរមកពីខាងក្រៅ ព្រះនគរ ដរាបដល់មណ្ឌបខាងក្នុងព្រះនគរ បានទ្រព្យ ប្រមាណមួយរយកោដិ ។

សកលជម្ពូទ្វីបក៏ល្បីលាន់ឮឡើង ។ ព្រះរាជា ទាំងឡាយគិតថា យើងនឹងធ្វើការអភិសេកដោយទឹក លាងជើងរបស់ព្រហ្មបជាបតី ទ្រង់បញ្ជូនទ្រព្យ ១ សែនកហាបណៈ ទៅ ទើបបានទឹកនោះ ។ កាលនាង កំពុងនៅក្នុងមណ្ឌបនោះឯង ក៏ប្រសូតបុត្រ ។ កុមារ ដែលបានមកដោយអាស្រ័យព្រះមហាបុរស មានរូប ថ្លាផូរផង់ ដល់ព្រមដោយលក្ខណៈ។ សកលជម្ពូទ្វីបក៏ កើតកោលាហលព្រមជាមួយគ្នាថា បុត្ររបស់ស្តេច មហាព្រហ្មកើតហើយ ។ ទ្រព្យដែលបានមកអំពី

មនុស្សនោះ ៗ ប្រមាណពាន់កោដិ ដោយប្រាថ្នាថា នឹងជាតម្លៃ**ខីរមណី** (គឺតម្លៃទឹកដោះ) សម្រាប់កុមារ សូម្បីនិវេសន៍ក៏សម្រេចដោយទ្រព្យមានប្រមាណត្រឹមតែប៉ុណ្ណោះ ។ មនុស្សទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងដាក់នាមដល់កុមារ ហើយតាក់តែងនិវេសន៍, ឲ្យកុមារងូតដោយទឹកប្រអូប, ប្រដាប់ហើយ ក៏ដាក់នាមថា **មណ្ឌព្យៈ** ព្រោះកើតក្នុងមណ្ឌប ។

កុមារចម្រើនវ័យធំឡើងដោយសេចក្ដីសុខ ក៏ដល់វ័យរៀនសូត្រសិល្បសាស្ត្រ អ្នកប្រាជ្ញអ្នកចេះដឹងវិជ្ជាក្នុងសកលជម្ពូទ្វីបមកកាន់សម្នាក់កុមារ ឲ្យកុមារសិក្សាសិល្បវិជ្ជា។ កុមារឆ្លាតឈ្លាសមានបញ្ញា រៀនសូត្រសិល្បវិជ្ជាត្រឹមតែការស្ដាប់ៗ មកហើយ ដូចជាការក្រងកែវមុក្តា ។ សិល្បវិជ្ជាដែលរៀនសូត្រទុក

ហើយ ក៏ចងចាំទុក ដូចជាប្រេងដែលដាក់ក្នុងថ្លាំង មាស ។ ដរាបដល់បរិយត្តិរត់មាត់ ព្រោះហេតុនោះ បរិយត្តិដែលឈ្មោះថា មិនបានរៀនសូត្រ រមែងមិន មាន ។ ព្រាហ្មណ៍ទាំងឡាយហៃហាមកុមារត្រាប់ទៅ សូម្បីកុមារនោះក៏ជាអ្នកដែលព្រាហ្មណ៍ចិញ្ចឹមរក្សា ហើយ ។ ព្រាហ្មណ៍ ៨ ម៉ឺននាក់ តែងទទួលនិច្ចភត្តក្នុង ផ្ទះរបស់កុមារ។ ផ្ទះរបស់កុមារធំសម្បើមណាស់ មាន ខ្លោងទ្វារធំដល់ទៅ ៧ ។ ទ្រព្យដែលមនុស្សក្នុងជម្ពូទ្វីប បញ្ជូនឲ្យក្នុងថ្ងៃមង្គលមានប្រមាណរាប់១ពាន់កោដិ ។

ចំណែកព្រះពោធិសត្វពិចារណាថា កុមារ ប្រមាទ ឬមិនប្រមាទហ្ន៎ ក៏ជ្រាបរឿងរ៉ាវរបស់កុមារ នោះសព្វគ្រប់ ។ លោកគិតថា កុមារដែលកើតហើយ នេះ ត្រូវព្រាហ្មណ៍ចិញ្ចឹមទុក ទានដែលឲ្យក្នុងខេត្ត

ណាមានផលច្រើន គេមិនដឹងដល់ខេត្តនោះទេ យើង
នឹងទៅទូន្មានគេ ។ រួចព្រះពោធិសត្វដណ្ដប់ចីវរ កាន់
ភាជន៍ដាក់អាហារ គិតថា ខ្លោងទ្វារទាំងឡាយចង្អៀត
ណាស់ យើងមិនអាចចូលទៅតាមខ្លោងទ្វារបានទេ
ទើបនឹងទៅតាមផ្លូវអាកាស ចុះក្នុងទីដែលពួក
ព្រាហ្មណ៍ប្រមាណ ៨០០០០ នាក់បរិភោគអាហារ ។
ចំណែកមណ្ឌព្យកុមារឲ្យអ្នកបម្រើចាប់វែកមាស
ហើយអង្គាសខ្លួនឯងដោយបង្គាប់ថា ពួកអ្នកចូរឲ្យ
បាយត្រង់នេះ ឲ្យសម្លត្រង់នេះ គ្រាន់តែឃើញព្រះ
ពោធិសត្វភ្លាម ក៏ក្រោធ ដូចជាពស់ពិសត្រូវវាយ
ដោយដំបង ទើបពោលគាថានេះថា ៖

ក្កុតោ នុ អាគច្ឆសិ ទុម្មវាសី,
ឱតល្លកោ បំសុបិសាចកោវ;

**សង្ការចោឡំ បដិមុញ្ច កណ្ឋេ,**
**កោ រេ តុវំ ហោសិ អទក្ខិណេយ្យោ ។**

*អ្នកមកពីទីណា បានជាមានប្រដាប់ស្លៀកពាក់ អាក្រក់លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវ កំណាត់សំពត់ ដែលគេចោលលើគំនរសំរាមព្ធដ៏ក ខ្លួន អ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជាទក្ខិណេយ្យបុគ្គល ទេ ។*

*ព្រះមហាសត្វមិនក្រោធ កាលទូន្មានកុមារ ទើបពោលថា ៖*

**អន្នំ តវេទំ បកតំ យសស្សិ,**
**តំ ខជ្ជរេ ភុញ្ជរេ បិយ្យរេ ច;**
**ជានាសិ មំ ត្វំ បរទត្តុបជីវឹ,**
**ឧត្តិដ្ឋ បិណ្ឌំ លភតំ សបាកោ ។**

គ្រឿងបរិភោគនេះបរិបូណ៌ដោយបរិវារ អ្នកបានតាក់តែងហើយ ពួកជនតែងទំពាស៊ី បរិភោគផឹកនូវគ្រឿងបរិភោគនោះ អ្នកស្គាល់ហើយនូវយើងថាជាអ្នកចិញ្ចឹមជីវិត ដោយសាអ្នកដទៃឲ្យ សូមឲ្យមនុស្សចណ្ឌាលបាននូវដុំបាយដែលបុគ្គលគប្បីទៅឈរជិត។

មណ្ឌព្យកុមារនោះ កាលសម្តែងថា បាយនេះមិនបានចាត់ចែងទុកសម្រាប់មនុស្សដូចលោក ទើបពោលថា ៖

អន្នំ ឞមេឞំ បកតំ ព្រាហ្មណានំ,
អត្ថត្ថិតំ សទ្ធហតោ ឞមេឞំ;
អបេហិ ឯត្តោ កិមិធដ្ឋិតោសិ,
ន មាទិសា តុយ្ហំ ទទន្តិ ជម្ម ។

គ្រឿងភោជននេះ ខ្ញុំបានតាក់តែងបម្រុងពួក
ព្រាហ្មណ៍ នេះជាភោជនរបស់ខ្ញុំ ដែលជឿចំពោះ
សេចក្ដីចម្រើនរបស់ខ្លួន អ្នកចូរចៀសចេញអំពីទីនេះ
អ្នកមកឋិតនៅក្នុងទីនេះធ្វើអ្វី នៃបុគ្គលថោកទាប
បុគ្គលទាំងឡាយប្រហែលយើង មិនឲ្យភោជនដល់អ្នក
ទេ ។

គ្រានោះ ព្រះពោធិសត្វសម្ដែងថា ធម្មតាទាន
អ្នកគួរឲ្យដល់បុគ្គលណាមួយ ទាំងដែលមានគុណធម៌
ទាំងដែលមិនមានគុណធម៌ ដូចយ៉ាងថា ពូជដែលគេ
ដាំចុះ ក្នុងទីទំនាបក្ដី ទីទួលក្ដី អាស្រ័យរសដី និងរស
ទឹក រមែងដុះចេញផ្លែយ៉ាងណា ទានដែលឈ្មោះថា
គ្មានផលរមែងមិនមាន ដូច្នោះ ទានដែលឲ្យដល់អ្នក
មានគុណធម៌ រមែងមានផលចម្រើន ដូចពូជដែល

សាបព្រោះចុះក្នុងទីស្រែល្អ ដូច្នោះ ទើបពោលគាថានេះថា ៖

ថលេ ច និន្នេ ច វបន្តិ ពីជំ,
អនូបខេត្តេ ផលមាសមានា;
ឯតាយ សទ្ធាយ ទទាហិ ទានំ,
អប្បេវ អារាធយេ ទក្ខិណេយ្យេ ។

ពួកអ្នកប្រាថ្នាផលស្រូវ រមែងព្រោះពូជក្នុងទីទួលឬទំនាប និងទីដែលមិនមែនជាស្រែ អ្នកចូរឲ្យទានដោយសទ្ធាបែបនេះចុះ សូមអ្នកញ៉ាំងទក្ខិណេយ្យបុគ្គលឲ្យត្រេកអរ ផង ។

លំដាប់នោះ កុមារក្រោធក្រៃលែងឡើង សម្លុតអ្នករក្សាទ្វារជាដើមថា អ្នកណាឲ្យមនុស្សក្បាលត្រងោលនេះចូលមក ហើយពោលគាថាថា ៖

ខេត្តានិ មយ្ហំ វិទិតានិ លោកេ,
យេសាហំ ពីជានិ បតិដ្ឋបេមិ;
យេ ព្រាហ្មណា ជាតិមន្តូបបន្នា,
តានីធ ខេត្តានិ សុបេសលានិ ។

យើងព្រោះពូជទាំងឡាយក្នុងស្រែណា ស្រែទាំងនោះក្នុងលោក យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នកប្រកបដោយជាតិនិងមន្ត ពួកព្រាហ្មណ៍ទាំងនោះ មានសីល ជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

(ព្រះមហាបុរសពោលថា ៖

ជាតិមទោ ច អតិមានិតា ច
លោភោ ច ទោសោ ច មទោ ច មោហោ
ឯតេ អគុណា យេសុ ច សន្តិ សព្វេ
តានីធ ខេត្តានិ អបេសលានិ ។

សេចក្ដីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គល
មើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្ដីស្រវឹង ១
មោហៈ ១ ទោសទាំងអស់នេះ មាននៅក្នុងពួកបុគ្គល
ណា បុគ្គលពួកនោះ មិនមែនជាអ្នកមានសីលជាទី
ស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុលោកនេះឡើយ ។

ជាតិមទោ ច អតិមានិតា ច
លោភោ ច ទោសោ ច មទោ ច មោហោ
ឯតេ អគុណា យេសុ ន សន្តិ សព្វេ
តានីធ ខេត្តានិ សុបេសលានិ ។

សេចក្ដីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គល
មើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្ដីស្រវឹង ១
មោហៈ ១ ទោសទាំងអស់នេះ មិនមានក្នុងពួកបុគ្គល
ណា បុគ្គលពួកនោះ ទើបឈ្មោះថាមានសីលជាទី
ស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

*មណ្ឌព្យកុមារពោលថា*

**ក្វេត្ថ គតា ឧបជោតិយោ ច,**
**ឧបជ្ឈាយោ ច អថវា គណ្ឌកុច្ឆិ,**
**ឥមស្ស ទណ្ឌញ្ច វធញ្ច ទត្វា,**
**គលេ គហេត្វា ខលយាថ ជម្មំ ។**

*(ឆ្មាំទ្វារ ៣ នាក់) ឈ្មោះឧបជោតិយៈ ១ ឈ្មោះឧបជ្ឈាយៈ ១ ឈ្មោះគណ្ឌកុច្ឆិ ១ នៅក្នុងទីណា អ្នកទាំងឡាយចូរវាយសម្លាប់នូវមនុស្សលាមកនេះ ហើយចាប់ត្រង់ក អូសទាញចេញទៅ ។*

*រួចហើយបង្គាប់ថា ពួកអ្នកឯងចូរវាយមនុស្សថោកទាបនេះដោយឈើ ទាញគេត្រង់កអូសចេញទៅខាងក្រៅ ឲ្យផុតខ្លោងទ្វារទាំង ៧ ។*

ព្រះមហាបុរស កាលនាយឆ្មាំទ្វារទាំង៣នោះមកមិនទាន់ដល់សម្នាក់របស់ខ្លួន លោកក៏ហោះឡើងឈរឋិតនៅលើអាកាសពោលនឹងមណ្ឌពក្យកុមារនោះថា ៖

**គិរឹ នខេន ខណសិ,**
**អយោ ទន្តេហិ ខាទសិ;**
**ជាតវេទំ បទហសិ,**
**យោ ឥសឹ បរិភាសសិ ។**

អ្នកណាជេរប្រទេចនូវឥសី អ្នកនោះឈ្មោះថាជីកភ្នំ ដោយក្រចក ឈ្មោះថាខាំទំពាដែកដោយធ្មេញ ឈ្មោះថាព្យាយាមលេបភ្លើង ។

គ្រាពោលយ៉ាងនេះហើយ លោកត្រិះរិះថា បើកុមារនេះនឹងគប្បីឲ្យគេចាប់យើង ត្រង់ដៃ ឬត្រង់ជើង

នឹងធ្វើទុក្ខឲ្យកើតឡើង គប្បីប្រសព្វបាបដ៏ច្រើន គិតហើយក៏ហោះទៅចុះត្រង់ចន្លោះផ្លូវ ។

ព្រះមានព្រះភាគទ្រង់សម្រេចព្រះសព្វញ្ញុត-ញ្ញាណ កាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថានេះថា ៖

ឥធំ វត្វាន មាតង្គោ,
ឥសិ សច្ចបរក្កមោ;
អន្តលិក្ខស្មឹ បក្កាមិ,
ព្រាហ្មណានំ ឧទិក្ខតំ ។

ឥសីឈ្មោះមាតង្គៈ ជាអ្នកមានសេចក្តីព្យាយាមទៀងទាត់ លុះពោលពាក្យនេះ ហើយក៏ចេញទៅឰដ៏អាកាស ចំពោះមុខពួកព្រាហ្មណ៍កំពុងក្រឡេកមើល ។

ក្នុងគ្រានោះ ទេវរាជជាប្រធាននៃពួកទេវតាអ្នករក្សាព្រះនគរ ក៏ពត់កមណ្ឌព្យកុមារៗ មុខរបស់គេក៏បែរទៅនៅខាងក្រោយ, ភ្នែកក៏ក្រឡាប់, ទឹកមាត់ក៏ហូរតាមមាត់, ខ្លួនរឹងដូចត្រូវលំពែងចាក់ ។ ពួកយក្ខដែលជាបរិវារចំនួន ៨០០០០ នាក់ ក៏ធ្វើដល់ព្រាហ្មណ៍ ទាំង ៨០០០០ នោះដូចគ្នា ។ ពួកយក្សទាំងនោះមិនសម្លាប់មណ្ឌព្យកុមារដោយសម្គាល់ថា គេជាបុត្ររបស់មាតង្គតសី ដូច្នេះគ្រាន់តែធ្វើឲ្យគេលំបាកវេទនាប៉ុណ្ណោះ ។ មនុស្សទាំងឡាយក៏ប្រញាប់ទៅប្រាប់ព្រហ្មបជាបតី ។ នាងទិដ្ឋមង្គលិកាប្រញាប់មក ឃើញអាការៈប្លែកៗនោះហើយ ក៏ពោលគាថានេះថា ៖

**អាវេធិតំ បិដ្ឋិតោ ឧត្តមង្គំ,**
**ពាហុំ បសារេតិ អកម្មនេយ្យំ;**

សេតានិ អដ្ឋីនិ យថា មតស្ស,
កោ មេ ឥមំ បុត្តមកាសិ ឯវំ ។

ក្បាល (របស់កូនអញ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅមិនគួរ ដល់ការងារ ភ្នែកទាំងឡាយសដូចជាបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនអញនេះ ឲ្យទៅ ជាយ៉ាងនេះ ។

មនុស្សទាំងឡាយប្រាប់នាងថា ៖

ឥធាគមា សមណោ ទុម្មវាសី,
ឱតល្លកោ បំសុបិសាចកោវ,
សង្ការចោឡំ បដិមុញ្ច កណ្ឋេ,
សោ តេ ឥមំ បុត្តមកាសិ ឯវំ ។

មានសមណៈ (មួយរូប) មកក្នុងទីនេះ មានប្រដាប់ស្លៀកពាក់អាក្រក់លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោលលើគំនរ

សំរាមព្នង់ក សមណៈនោះបានធ្វើនូវកូនរបស់នាងនេះឲ្យយ៉ាងនេះ ។

នាងបានស្តាប់ហើយ ក៏ដឹងច្បាស់ថា ស្វាមីអ្នកដែលឲ្យយសដល់យើងដឹងថា បុត្រប្រមាទ គង់នឹងមកដើម្បីអនុគ្រោះដល់បុត្រនោះទើបសួរឧបដ្ឋាកថា ៖

**កាតមំ ទិសំ អគមា ភូរិបញ្ញោ,**
**អក្ខាថ មេ មាណវា ឯតមត្ថំ;**
**គន្ត្វាន តំ បដិការេមុ អច្ចយំ,**
**អប្បេវ ធំ បុត្ត លភេមុ ជីវិតំ ។**

សមណៈមានប្រាជ្ញាក្រាស់ ដូចផែនដីនោះ ទៅក្នុងទិសដូចម្ដេច ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរប្រាប់នូវសេចក្តីនុ៎ះដល់ខ្ញុំ យើងនឹងទៅ

សូមខមាទោស ចំពោះសមណៈនោះ ធ្វើម្ដេចហ្ន៎ យើង នឹងបានកូននោះ មានជីវិតរស់នៅ ។

អ្នកទាំងនោះប្រាប់ថា ៖

វេហាយសំ អគមា ភុរិបញ្ញោ,
បថទ្ធុនោ បន្នរសេវ ចន្ទោ;
អបិចាបិ សោ បុរិមទិសំ អគច្ឆិ,
សច្ចប្បដិញ្ញោ ឥសិ សាធុរូបោ ។

សមណៈមានប្រាជ្ញាក្រាស់ដូចផែនដីបានទៅ ក្នុងអាកាស ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដើរទៅតាម ផ្លូវនៃអាកាស មួយទៀត សមណៈនោះជាឥសី មាន ការប្ដេជ្ញាដ៏ទៀងទាត់ មានសភាពដ៏ល្អ បានទៅកាន់ ទិសខាងកើតហើយ ។

ចំណែកព្រះមហាបុរសអធិដ្ឋានថា ស្លាកទី ដែលចុះត្រង់ចន្លោះផ្លូវ ស្នាមជើងរបស់យើង ចូរកុំបាត់ ដោយអំណាចនៃដំរីសេះជាដើមឡើយ នាងទិដ្ឋមង្គលិកាបុណ្ណោះ ចូរឃើញយើង អ្នកដទៃកុំឃើញ ហើយលោកចេញបិណ្ឌបាត ទទួលបាយល្មមទ្រទ្រង់ជីវិត អង្គុយបរិភោគត្រង់សាលាសម្នាក់របស់អ្នកធ្វើដំណើរ ដាក់អាហារដែលសល់ពីបរិភោគបន្តិចទុកក្នុងភាជនៈដាក់អាហារនុ៎ះឯង ។ សូម្បីនាងទិដ្ឋ-មង្គលិកា ចុះអំពីប្រាសាទដើរទៅ តាមចន្លោះផ្លូវ ជួបស្នាមជើង ក៏ដឹងថា នេះស្នាមជើងរបស់តាបសដែលឲ្យយសដល់ខ្លួន ក៏ដើរទៅតាមស្នាមជើង (ជួបហើយ) ថ្វាយបង្គំ រួចពោលថា បពិត្រលោកម្ចាស់ សូមលោកមេត្តាលើកទោសកំហុសដែលទាសៈរបស់ខ្ញុំធ្វើផង់ចុះ លោកក៏ឈ្មោះថាមិននៅក្នុងអំណាចនៃសេចក្តីក្រោធ

មេត្តាឲ្យជីវិតដល់បុត្ររបស់ខ្ញុំផង ហើយនាងពោល យ៉ាងនេះថា ៖

អាវេឋិតំ បិដ្ឋិតោ ឧត្តមង្គំ,
ពាហុំ បសារេតិ អកាម្មនេយ្យំ;
សេតានិ អក្ខីនិ យថា មតស្ស,
កោ មេ ឥមំ បុត្តមកាសិ ឯវំ ។

ក្បាល (របស់កូនខ្ញុំ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំងឡាយសដូចភ្នែកបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនខ្ញុំនេះ ឲ្យទៅជា យ៉ាងនេះ ។

ព្រះមហាសត្វពោលថា ៖

យក្ខា ហវេ សន្តិ មហានុភាវា,
អន្វាគតា ឥសយោ សាធុរូបា;

**តេ ទុដ្ឋចិត្តំ កុបិតំ វិទិត្វា,**
**យក្ខា ហិ តេ បុត្តមកំសុ ឯវំ ។**

*ពួកយក្សមានអនុភាពច្រើន (មកដោយគិតថា) ពួកឥសីមានសភាពដ៏ល្អ មកហើយ (ក្នុងទីនេះ) ពួកយក្ខដឹងថា (កូនរបស់នាង) មានចិត្តប្រទូស្ត ក្រោធខឹង ហើយបានធ្វើនូវកូននាងឲ្យយ៉ាងនេះ ។*

*ព្រះមហាបុរសពោលថា យើងមិនធ្វើយ៉ាងនោះទេ តែកាលពួកភូត ពួកយក្ខ និងទេវតាអ្នកគោរពក្នុងអ្នកបួស ឃើញជនបៀតបៀនអ្នកបួស បានធ្វើយ៉ាងនោះ ។*

*នាងទិដ្ឋមង្គលិកាពោលថា ៖*

**យក្ខា ច មេ បុត្តមកំសុ ឯវំ,**
**ត្វញ្ញេវ មេ មា កុទ្ធោ ព្រហ្មចារិ;**

**តុម្ហេវ ចាគេ សរណំ គតាស្មិ,**

**អញ្ញាគតា បុត្តសោកេន ភិក្ខុ ។**

*បើពួកយក្ខបានធ្វើកូនរបស់ខ្ញុំឲ្យយ៉ាងនេះហើយ សូមលោកជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កុំខឹងចំពោះខ្ញុំ នាងខ្ញុំជាស្រី សូមដល់នូវបាទារបស់លោកជាទីពឹង បពិត្រភិក្ខុ ខ្ញុំមកដោយសេចក្តីសោកចំពោះកូន។*

*នាងពោលថា បពិត្រលោកម្ចាស់ លោកជាអ្នកមិនមានចិត្តប្រទូសរ៉ាយ គង់ជាពួកទេវតាធ្វើពិត ពួកទេវតា គឺខ្ញុំមិនអាចសូមខមាទោសបានដោយងាយទេ ខ្ញុំនឹងបដិបត្តិយ៉ាងណា លោកម្ចាស់ ។*

*ព្រះមហាសត្វពោលថា ៖*

**តទេវ ហិ ឯតរហិ ច មយ្ហំ,**

**មនោបទោសោ ន មមត្ថិ កោចិ;**

បុត្តោ ច តេ វេទមនេន មត្តោ,
អត្ថំ ន ជានាតិ អជិច្ច វេទេ ។

កាលនោះក៏ដោយ ឥឡូវនេះក៏ដោយ យើងមិនមានការប្រទូស្តក្នុងចិត្តតិចតួចទេ តែកូនរបស់នាងជាអ្នកស្រវឹង ដោយសេចក្តីស្រវឹងក្នុវេទ រៀនវេទហើយមិនស្គាល់សេចក្តីចម្រើន ។

នាងទិដ្ឋមង្គលិកាពោលថា ៖

អទ្ធា ហវេ ភិក្ខុ មុហុត្តកេន,
សម្មុយ្ហតេវ បុរិសស្ស សញ្ញា;
ឯកាបរាធំ ខម ភូរិបញ្ញ,
ន បណ្ឌិតា កោធពលា ភវន្តិ ។

បពិត្រភិក្ខុ សញ្ញារបស់បុរសរមែងភ្លេចភ្លាំងដោយមួយរំពេចជាប្រាកដ បពិត្រលោកមានប្រាជ្ញា

ក្រាស់ដូចផែនដី សូមលោកអត់នូវទោសកំហុសម្តងចុះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនមានក្រោធជាកម្លាំង ។

ព្រះមហាសត្វកាលនឹងអត់ទោសឲ្យព្រាហ្មណ៍ទាំងនោះ ក៏ពោលនឹងនាងទិដ្ឋមង្គលិកាថា យើងនឹងឲ្យថ្នាំអមតៈ ដើម្បីជាប្រយោជន៍ឲ្យពួកយក្សរត់ចេញ ដូច្នេះទើបពោលគាថាថា

ឥទញ្ច មយ្ហំ ឧត្តិដ្ឋបិណ្ឌំ,
តវ មណ្ឌព្យោ ភុញ្ជតុ អប្បបញ្ញោ;
យក្ខា ច តេ នំ ន វិហេឋយេយ្យុំ,
បុត្តោ ច តេ ហោហិតិ សោ អរោគោ ។

ចូរឲ្យមណ្ឌព្យកុមារ ដែលជាបុគ្គលមានប្រាជ្ញាតិច ជាបុត្តរបស់នាង បរិភោគនូវដុំបាយ ដែលយើងឈរហើយបានមកនេះ ចំណែកខាងពួកយក្ខនឹងលែង

បៀតបៀននូវកូនរបស់នាង ទាំងកូនរបស់នាងនោះ នឹងទៅជាបុគ្គលមិនមានរោគ ។

ព្រះមហាបុរសពោលថា បើដូច្នោះ យើងនឹងប្រាប់ថ្នាំដល់នាង អាហារដែលសល់ពីយើងបរិភោគនេះ នៅមានក្នុងភាជនៈដាក់អាហាររបស់យើង នាងចូរចាក់ទឹកបន្តិច យកទៅដាក់ក្នុងមាត់កូនរបស់នាង អាហារដែលនៅសល់យកដាក់ក្នុងភាជនៈទឹក រួចយកទៅបន្តក់ដាក់ក្នុងមាត់ពួកព្រាហ្មណ៍ ៨ ម៉ឺននាក់ចុះ ។ នាងទទួលពាក្យថា ខ្ញុំនឹងធ្វើតាមយ៉ាងនោះ, នាងកាន់យកអាហារ ហើយសំពះព្រះមហាបុរស, ទៅហើយក៏បានធ្វើយ៉ាងនោះ។

ពេលដែលនាងទិដ្ឋមង្គលិកាដាក់អាហារក្នុងមាត់មណ្ឌព្យកុមារហើយ ទេវរាជជាប្រធានដឹងថា កាលតាបសធ្វើថ្នាំដោយខ្លួនឯង ពួកយើងមិនអាចធ្វើ

អ្វីបានឡើយ ក៏លែងកុមារនោះទៅ ។ ចំណែកមណ្ឌព្យ-
កុមារលេបអាហារហើយ ក៏មានអាការៈជាប្រក្រតី ដូច
មិនធ្លាប់មានទុក្ខអ្វីៗឡើយ។ បន្ទាប់មក នាងក៏ឲ្យគេ
ដាក់អាហារដែលនៅសល់ក្នុងភាជន៍ទឹក រួចយកទៅ
បន្តក់ក្នុងមាត់ព្រាហ្មណ៍ទាំងឡាយ ។ ពួកយក្ខក៏លែង
ពួកព្រាហ្មណ៍ ហើយចៀសចេញទៅ ។ ពេលនោះ
នាងទិដ្ឋមង្គលិកាពោលនឹងកូនថា កូនអើយ ចូរមើល
អាការៈប្លែកៗរបស់ពួកព្រាហ្មណ៍ប្រចាំត្រកូលរបស់
កូនឯង ដែលប្រាសចាកហិរិឱត្តប្បៈនេះ សមណៈ
ទាំងឡាយរមែងមិនមានសភាពបែបយ៉ាងនេះទេ កូន
គប្បីឲ្យពួកសមណៈដែលជាទក្ខិណេយ្យបុគ្គលឆាន់
ចុះ ។ រួចនាងទូន្មានកូនថា ៖

មណ្ឌព្យ ពាលោសិ បរិត្តបញ្ញោ,
យោ បុញ្ញក្ខេត្តានមកោវិទោសិ;
មហាក្កសាវេសុ ទទាសិ ទានំ,
កិលិដ្ឋកម្មេសុ អសញ្ញតេសុ ។

ម្នាលមណ្ឌព្យៈ អ្នកជាបុគ្គលពាលមានប្រាជ្ញាស្តួចស្តើង អ្នកជាបុគ្គលមិនស្គាល់ នូវបុញ្ញក្ខេត្តទាំងឡាយ អ្នកឲ្យទានចំពោះតែពួកជន ដែលមានទឹកចត់គឺកិលេសដ៏ច្រើន មានអំពើសៅហ្មង ជាអ្នកមិនសង្រួម ។

ជដា ច កេសា អជិនា និវត្ថា,
ជរូទបានំវ មុខំ បរូឡ្ហំ;
បជំ ឥមំ បស្សថ ទុម្មរូបំ,
ន ជដាជិនំ តាយតិ អប្បបញ្ញំ ។

(ពួកជនខ្វះ) បួងសក់ ស្លៀកនូវស្បែកខ្លាឃ្មុំ មានមុខទ្រុបទ្រុល (ដោយពុកមាត់ពុកចង្កា) ដូចរណ្ដៅទឹកដ៏ចាស់ អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសភាពអាក្រក់នេះចុះ ត្បិតក្នុងសក់និងស្បែកខ្លាឃ្មុំ ការពារនូវបុគ្គល ដែលមានប្រាជ្ញាតិច មិនបានទេ ។

យេសំ រាគោ ច ទោសោ ច,
អវិជ្ជា ច វិរាជិតា;
ខីណាសវា អរហន្តោ,
តេសុ ទិន្នំ មហប្ផលំ ។

ពួកបុគ្គលណា លះបង់រាគៈ ទោសៈ និងអវិជ្ជា ពួកបុគ្គលនោះ ឈ្មោះថា ជាអរហន្តខីណាស្រព ទានដែលបុគ្គលឲ្យចំពោះពួកបុគ្គលទាំងនោះ ទើបជាទានមានផលច្រើន ។

ពួកព្រាហ្មណ៍លេបអាហារហើយ ក្រោកឡើង សួរថា យកអ្វីដាក់មាត់ពួកយើង? គេប្រាប់ថា អាហារជាសំណល់របស់មាតង្គឥសី ។ ព្រាហ្មណ៍ទាំងនោះគិតថា "មនុស្សទាំងឡាយនឹងមិនគប់រកពួកយើង ដោយសម្គាល់ថា ព្រាហ្មណ៍ទាំងនេះមិនមែនជាព្រាហ្មណ៍បរិសុទ្ធទៀតទេ ព្រោះយើងត្រូវគេឲ្យបរិភោគអាហារសំណល់ពីមនុស្សចណ្ឌាល ឥឡូវនេះមិនមែនជាព្រាហ្មណ៍អំពីកំណើតទៀតឡើយ" ដូច្នេះហើយក៏នាំគ្នារត់ចេញចាកទីនោះ ទៅកាន់ដែនមជ្ឈៈ រំពឹងថា ពួកយើងនឹងមានឈ្មោះថាព្រាហ្មណ៍ឡើងវិញដោយការបូជាភ្លើងក្នុងនគររបស់ព្រះបាទមជ្ឈៈ។

ក្នុងសម័យនោះ ព្រះពោធិសត្វ (ជាអ្នក) ធ្វើនូវការសង្កត់សង្កិនមនុស្សអាក្រក់ និងទូន្មានអ្នកមាន

មានះព្រោះជាតិ ។ មានតាបសមួយរូបឈ្មោះ **ជាតិមន្ត** សម្គាល់ខ្លួនឯងថា មិនមានអ្នកណាស្មើ មិនធ្វើការរាប់អានអ្នកដទៃ ។ ព្រះពោធិសត្វជួបតាបសនោះនៅត្រង់ច្រាំងទន្លេគង្គា ក៏ដើរទៅក្នុងទីនោះ ដោយបំណងនឹងគ្រុបសង្កត់មានះរបស់តាបសនោះ ។ ជាតិមន្តតាបសសួរថា អ្នកដ៏ចម្រើនមានជាតិអ្វី ? ពោធិសត្វតបថា ខ្ញុំជាចណ្ឌាល លោកអាចារ្យ ។ ជាតិមន្តតាបសក៏បណ្ដេញថា ថយចេញ តាបស-ចណ្ឌាល ចូរទៅនៅខាងក្រោមទន្លេគង្គា កុំធ្វើទឹកខាងលើទន្លេគង្គាឲ្យជាសំណល់ឡើយ ។

ព្រះពោលសត្វទទួលថា ល្អណាស់ លោក-អាចារ្យ ខ្ញុំនឹងនៅក្នុងទីដែលលោកប្រាប់ ហើយក៏ទៅនៅខាងក្រោមទន្លេគង្គា រួចអធិដ្ឋានថា ទឹកទន្លេគង្គា

ចូរហូរប្រាសក្រសែទឹក ។ ព្រឹកឡើង ជាតិមន្តតាបស ចុះទៅកាន់ទន្លេគង្គា ខ្ពុរមាត់ លាងមុខ ជម្រះជដា ។ ព្រះពោធិសត្វទំពាឈើស្ទន់ ស្តោះទឹកមាត់ជាដុំៗ ដាក់ក្នុងទឹក ។ ឈើស្ទន់និងទឹកមាត់ ក៏អណ្តែតទៅលើ ជាតិមន្តតាបស ។ ព្រះពោធិសត្វអធិដ្ឋានថា ឈើស្ទន់និងទឹកមាត់នោះ កុំជាប់ក្នុងទីដទៃ ឲ្យជាប់នៅត្រង់ជដារបស់តាបសនោះតែម្នាក់ ទាំងទឹកមាត់ ទាំងឈើស្ទន់ ក៏ជាប់នៅត្រង់ជដារបស់តាបសនោះឯង ។

ជាតិមន្តតាបសមួម៉ៅក្តៅក្រហាយចិត្តថា អំពីនេះជារបស់តាបសចណ្ឌាលដោយពិត ទើបដើរទៅសួរថា នៃមនុស្សចណ្ឌាល ទឹកទន្លេគង្គានេះ អ្នកឯងធ្វើឲ្យវាហូរបញ្ច្រាស់ឬ ។ ព្រះពោធិសត្វឆ្លើយថា ករុណា លោកអាចារ្យ ។ ជាតិមន្តតាបសពោលថា បើ

ដូច្នោះ អ្នកកុំនៅខាងក្រោមទន្លេគង្គាឡើយ ចូរនៅខាងលើទន្លេគង្គាវិញ ។ ព្រះពោធិសត្វទទួលពាក្យថា សាធុលោកអាចារ្យ ខ្ញុំនឹងនៅក្នុងទីតាមដែលលោកប្រាប់ ហើយក៏នៅក្នុងទីនោះ លោករំសាយឫទ្ធិចេញ, ទឹកក៏ហូរតាមប្រក្រតី ។ ជាតិមន្តតាបសក៏ប្រសព្វសេចក្ដីវិនាសម្ដងទៀត ។ ជាតិមន្តតាបសទៅសួរព្រះពោធិសត្វថា នៃតាបសចណ្ឌាល ទឹកទន្លេគង្គានេះ អ្នកធ្វើឲ្យវាហូរបញ្ច្រាស់ក្នុងគ្រាខ្លះ គ្រាខ្លះក៏ធ្វើឲ្យវាហូរតាមក្រសែទឹកឬ ។ ព្រះពោធិសត្វឆ្លើយថា ករុណាលោកអាចារ្យ ។ ជាតិមន្តតាបសទើបដាក់បណ្ដាសាថា អ្នកឯងមិនឲ្យអ្នកបួសនៅជាសុខ ក្បាលរបស់អ្នកចូរបែកជា ៧ ភាគ ក្នុងថ្ងៃទី ៧ ចុះ ។ ព្រះពោធិសត្វពោលថា ល្អណាស់លោកអាចារ្យ ចំណែកខាងខ្ញុំនឹងមិនឲ្យព្រះអាទិត្យរះឡើងឡើយ ។

គ្រានោះ ព្រះមហាសត្វគិតថា "ពាក្យបណ្ដាសា នឹងធ្លាក់លើសីសៈរបស់តាបសនោះប៉ុណ្ណោះ យើងនឹងរក្សាតាបសនោះ" ថ្ងៃស្អែក មិនឲ្យព្រះអាទិត្យរះឡើងដោយឫទ្ធិ ព្រោះសេចក្ដីអាណិត។ ធម្មតាឥទ្ធិ-វិស័យរបស់អ្នកមានឫទ្ធិ ជាអចិន្តេយ្យ (មិនគួរគិត) តាំងពីនោះមក ដំណើររះឡើងរបស់ព្រះអាទិត្យរមែងមិនប្រាកដ, ការកំណត់ពេលយប់ពេលថ្ងៃ មិនមាន, មិនមានការប្រកបការងារ ដូចធ្វើស្រែ ធ្វើជំនួញជាដើម ។

មនុស្សទាំងឡាយដល់សេចក្ដីអន្តរាយ ដោយមិនដឹងថា នេះយក្ខ ភូតបិសាច ទេវតា នាគ ឬគ្រុឌ ជាអ្នកបណ្ដាល ក៏គិតគ្នាថា "គួរធ្វើយ៉ាងណាហ្ន៎" ប្រឹក្សាគ្នាថា ធម្មតាថា រាជត្រកូលមានបញ្ញាច្រើន នឹងអាច

គិតប្រយោជន៍ដល់ប្រជារាស្ត្របាន, ពួកយើងទៅកាន់រាជត្រកូលទាំងអស់គ្នា ហើយក៏នាំគ្នាទៅកាន់រាជ-ត្រកូលស្រែករៀបរាប់អំពីរឿងនោះ ។ ព្រះរាជាស្ដាប់ហើយសូម្បីទ្រង់តក់ស្លុតក៏ធ្វើជាមិនខ្លាច ត្រាស់ថា អ្នកទាំងឡាយកុំព្រួយបារម្ភអី តាបសឈ្មោះជាតិមន្តនៅមាត់ច្រាំងទន្លេគង្គា គង់នឹងដឹងហេតុភេទនោះ យើងនឹងទៅសួរលោកឲ្យអស់សង្ស័យ ។ កន្លងទៅ ២-៣ ថ្ងៃព្រះរាជានិងអ្នកប្រព្រឹត្តអំពើជាប្រយោជន៍ ចូលទៅរកតាបស បានទទួលបដិសណ្ឋារៈហើយ ក៏ត្រាស់សួររឿងនោះ។ តាបសទូលថា ថ្វាយព្រះពរមហាបពិត្រមានចណ្ឌាលម្នាក់ ធ្វើទឹកទន្លេគង្គានេះ គ្រាខ្លះក៏ហូរតាមបណ្ដោយក្រសែទឹក គ្រាខ្លះក៏ឲ្យហូរបញ្ច្រាស់ពាក្យអ្វី ៗ ដែលអាត្មាពោលដើម្បីប្រយោជន៍នោះ ក៏

មានហើយ សូមមេត្តាត្រាស់សួរចណ្ឌាលម្នាក់នោះ គេគង់នឹងដឹង ។

ព្រះរាជាយាងទៅកាន់សម្នាក់មាតង្គឥសី ហើយត្រាស់សួរថា លោកម្ចាស់ដ៏ចម្រើន លោកមិនឲ្យព្រះអាទិត្យរះឡើងឬ? ព្រះពោធិសត្វទូលថា ថ្វាយព្រះពរ មហាបពិត្រ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វីលោកម្ចាស់ ។ ព្រះពោធិសត្វទូលថា ព្រោះជាតិមន្ត-តាបស បពិត្រមហារាជ ទាល់ឲ្យជាតិមន្តតាបសមកថ្វាយបង្គំ សូមទោសអាត្មា ។ ព្រះរាជាយាងទៅ ហើយត្រាស់ថា មកចុះលោកអាចារ្យ សូមលោកទៅសុំខមាទោសមាតង្គឥសី ។ ជាតិមន្តតាបសទូលថា មហាបពិត្រ អាត្មាមិនសំពះមនុស្សចណ្ឌាលទេ ។ ព្រះរាជាត្រាស់ថា កុំធ្វើយ៉ាងនេះឡើយ លោកអាចារ្យ

មេត្តាយល់មុខអ្នកជនបទផង ។ ជាតិមន្តតាបសក៏
បដិសេធយ៉ាងនោះទៀត ។ ព្រះរាជាស្ដេចចូលទៅរក
ព្រះពោធិសត្វ ត្រាស់ថា លោកអាចារ្យជាតិមន្តមិន
ប្រាថ្នាសូមខមាទោសទេ ។ ព្រះពោធិសត្វទូលថា បើ
ជាតិមន្តតាបសមិនសូមទោស អាត្មាភាពក៏មិនលែង
ព្រះអាទិត្យដែរ។ ព្រះរាជាត្រាស់ថា "បើជាតិមន្ត-
តាបសមិនសូមខមាទោស, លោកមិនព្រមញុំាងព្រះ
អាទិត្យឲ្យរះឡើង, ប្រយោជន៍អ្វីដល់ពួកយើងដោយ
ជាតិមន្តតាបសនោះ, យើងនឹងយល់អ្នកស្រុក" ហើយ
ត្រាស់បង្គាប់ថា នៃអ្នកទាំងឡាយ ពួកលោកចូរទៅ
ចាប់ដៃជើងជាតិមន្តតាបសនោះ មកកាន់សម្នាក់
មាតង្គឥសី ឲ្យលោកសូមខមាទោស ដើម្បីអនុគ្រោះ
អ្នកជនបទ ។ ពួករាជបុរសទៅហើយ បានធ្វើយ៉ាង

នោះ នាំជាតិមន្តតាបសមក ឲ្យអង្គុយទៀបជើង មាតង្គឥសី ញ៉ាំងឲ្យសូមខមាទោស ។

ព្រះពោធិសត្វពោលថា អាត្មាភាពអត់ទោស ចំពោះអ្នកដែលគប្បីអត់ទោស ប៉ុន្តែពាក្យបណ្តាសា របស់ជាតិមន្តតាបស នឹងធ្លាក់លើសីសៈរបស់លោក កាលអាត្មាញ៉ាំងព្រះអាទិត្យឲ្យរះឡើង ពន្លឺរបស់ព្រះ អាទិត្យនឹងធ្លាក់លើសីសៈរបស់ជាតិមន្តតាបសនោះ បើដូច្នោះសីសៈរបស់តាបសនោះនឹងបែកចេញ ៧ ភាគ សូមឲ្យតាបសនោះកុំជួបសេចក្តីវិនាសនោះ ឡើយ លោកចូរចុះក្នុងទឹកប្រមាណត្រឹមក ចូរដាក់ដុំដី ស្អិតដ៏ធំទុកលើសីសៈ យើងនឹងលែងព្រះអាទិត្យ ពន្លឺ របស់ព្រះអាទិត្យជះត្រូវដុំដីស្អិត នឹងទម្លាយដុំដីស្អិត នោះបែកជា ៧ ភាគ ។ ឲ្យតាបសនោះចោលដុំដីស្អិត

ហើយមុជទឹក ទៅងើបឡើងត្រង់កំពុងដទៃ អ្នកទាំងឡាយចូរប្រាប់តាបសនោះ ធ្វើដូច្នេះតាបសនោះនឹងមានសេចក្ដីសួស្ដីរួចផុតពីក្ដីអន្តរាយ ។ មនុស្សទាំងឡាយទទួលពាក្យថា នឹងធ្វើយ៉ាងនោះ ហើយធ្វើក៏តាមបង្គាប់គ្រប់ប្រការ ។ សេចក្ដីសួស្ដីក៏មានដល់ជាតិមន្តតាបសនោះឯង ។ តាំងពីនោះមក ជាតិមន្ត-តាបសគិតថា ធម្មតាជាតិមិនមែនជាហេតុឡើយ គុណខាងក្នុងរបស់អ្នកបួសប៉ុណ្ណោះ ទើបជាហេតុពិត ដូច្នេះហើយក៏លះមានការប្រកាន់ជាតិនិងគោត្រឈប់ជាអ្នកស្រវឹងតទៅ ។

កាលជាតិមន្តតាបសត្រូវបានទូន្មានហើយ មហាជនក៏បានដឹងកម្លាំងរបស់ព្រះពោធិសត្វ កើតជាកោលាហលយ៉ាងធំ ។ ព្រះរាជាត្រាស់អង្វរសូមឲ្យព្រះ

ពោធិសត្វ ទៅកាន់ព្រះនគររបស់ព្រះអង្គ ។ ព្រះមហាសត្វថ្វាយប្ដេជ្ញាទទួលតាមពាក្យសូម ហើយគិតថា "នឹងទូន្មានព្រាហ្មណ៍ទាំង ៨ ម៉ឺន រូបនឹងដោះប្ដេជ្ញា" ហើយទៅកាន់នគររបស់ព្រះបាទមជ្ឈៈ ។

ព្រាហ្មណ៍ទាំងឡាយគ្រាន់តែឃើញព្រះពោធិសត្វភ្លាម ក៏ប្រឹក្សាគ្នាថា លោកដ៏ចម្រើន មហាចោរនោះឯងមកហើយ ឥឡូវនេះ នឹងធ្វើពួកយើងឲ្យប្រាកដ (បើកបង្ហាញថា) ពួកយើងទាំងអស់គ្នាស៊ីសំណល់ពីមនុស្សចណ្ឌាល មិនមែនជាព្រាហ្មណ៍ទៀតទេ បើដូច្នេះ ពួកយើងនឹងនៅក្នុងទីនេះមិនបាន យើងនឹងសម្លាប់វាចោល ហើយនាំគ្នាទៅគាល់ព្រះរាជាទូលថា សូមថ្វាយព្រះពរ សូមមហាបពិត្រមេត្តាកុំសម្គាល់អ្នកបួសចណ្ឌាលម្នាក់នេះថា ជាមនុស្សល្អ

ឲ្យសោះ អ្នកបួសចណ្ឌាលនេះចេះមន្តច្រើន ចាប់ផែនដីធ្វើឲ្យជាអាកាសក៏បាន ចាប់អាកាសធ្វើឲ្យជាផែនដីក៏បាន ធ្វើទីឆ្ងាយឲ្យមកជិតក៏បាន ធ្វើទីជិតឲ្យឆ្ងាយក៏បាន ធ្វើទន្លេគង្គាឲ្យហូរបញ្ច្រាស់ក៏បាន កាលប្រាថ្នាអាចត្រឡប់ផែនដីក៏បាន ឬថា ដែលឈ្មោះថាចិត្តរបស់អ្នកដទៃមិនអាចទុកចិត្តបានគ្រប់វេលាទេ អ្នកបួសចណ្ឌាលនេះកាលបានទីពឹងក្នុងនគរនេះ ក៏នឹងគប្បីធ្វើរាជសម្បត្តិរបស់ព្រះអង្គឲ្យវិនាសក៏បាន ធ្វើអន្តរាយព្រះជន្មជីវិតក៏បាន កាត់ផ្តាច់ព្រះរាជវង្សក៏បាន សូមមហាបពិត្រមេត្តាជឿពាក្យរបស់ពួកអាត្មាចុះគប្បីសម្លាប់វាក្នុងថ្ងៃនេះតែម្តងទៅ ក្រាបទូល ។

ធម្មតាព្រះរាជាទាំងឡាយរមែងមាន**បរបត្តិ**, ព្រះរាជានោះទើបស្តុងព្រះទ័យដោយអំណាចពាក្យ

ព្រាហ្មណ៍ទាំងនោះ ។ ចំណែកព្រះពោធិសត្វត្រាច់
បិណ្ឌបាតក្នុងនគរ ហើយឆាន់បាយដែលលាយដោយ
របស់ផ្សេងៗ ក្នុងទីដែលមានទឹកមួយកន្ទេង រួចហើយ
ដើរទៅកាន់ព្រះរាជឧទ្យាន ជាអ្នកប្រាសចាកសេចក្តី
សង្ស័យព្រោះជាអ្នកមិនមានកំហុស អង្គុយលើផ្ទាំង
សិលាដែលជាមង្គល ។ សតិរលឹកមិនបានក្នុងពេល
ត្រឹមមួយភ្លែត ព្រោះមិនបានពិចារណានៃញាណ
ដែលអាចរលឹកបាន ៨០ កប្ប គឺ ក្នុងអតីត ៤០ កប្ប
អនាគត ៤០ កប្ប ។ ព្រះរាជាមិនឲ្យអ្នកដទៃដឹង ស្តេច
យាងទៅដោយព្រះអង្គឯង ទ្រង់យកព្រះខាន់កាប់
ព្រះមហាបុរស ដែលអង្គុយភ្លេចខ្លួនព្រោះមិនបាន
ពិចារណា ដាច់ ២ កំណាត់ ។

*ទេវតាទាំងឡាយខឹងក្រោធ ក៏ញុំាងភ្លៀងផេះក្តៅឲ្យធ្លាក់ចុះក្នុងដែនមជ្ឈៈទាំងមូល ធ្វើដែននេះ ឲ្យមិនមែនជាដែន ។ ភ្លៀងលោហៈទី ៨ ភ្លៀងភក់ល្បាប់ទី ៩ ក៏ធ្លាក់ចុះក្នុងដែនរបស់ព្រះរាជាអង្គនោះ។ ភ្លៀង ៩ ប្រភេទ ធ្លាក់ចុះក្នុងដែនរបស់ព្រះរាជា ដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះព្រមទាំងបរិស័ទក៏កើតក្នុងមហានរក ។ ព្រោះហេតុនោះ សង្កិច្ចបណ្ឌិតទើបពោលថា ៖*

**ឧបហច្ច មនំ មជ្ឈោ,**
**មាតង្គស្មឹ យសស្សិនេ;**
**សបារិសជ្ជោ ឧច្ឆិន្នោ,**
**មជ្ឈារញ្ញំ តទា អហុ ។**

ស្តេចក្នុងដែនមជ្ឈៈ បៀតបៀននូវចិត្តរបស់មាតង្គតាបស ជាអ្នកមានយស ស្តេចក្នុងដែនមជ្ឈៈព្រមទាំងបរិស័ទក៏ដាច់សូន្យ ដែនឈ្មោះមជ្ឈៈក៏ទៅជាព្រៃក្នុងកាលនោះ ។

គប្បីជ្រាបថា ដែនមជ្ឈៈក្លាយជាព្រៃដោយប្រការដូច្នេះ ។ តែព្រៃមជ្ឈៈនោះ លោកហៅថា ព្រៃមាតង្គៈ ដោយអំណាចឥសីឈ្មោះមាតង្គៈ ។

មាតង្គពោធិសត្វ កាលស្លាប់ហើយ ក៏កើតក្នុងព្រហ្មលោក ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយទ្រង់ត្រាស់ថា

- **តទា មណ្ឌព្យោ ឧទេនោ អហោសិ**

  *មណ្ឌព្យកុមារក្នុងកាលនោះបានមកជាព្រះបាទឧទេន។*

- **មាតង្គបណ្ឌិតោ បន អហមេវ អហោសិំ** *ចំណែកមាតង្គបណ្ឌិត គឺតថាគតនេះឯង ។*

*(រៀបរៀងចាក គម្ពីរបបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ ឧបាលិសូត្រ និង ជាតកដ្ឋកថា ខុទ្ទកនិកាយជាតក វីសតិនិបាត មាតង្គជាតក)*

*ថ្ងៃអង្គារ ៣ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣, ចុល្លសករាជ ១៣៨១, មហាសករាជ ១៩៤១*
*ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ គ.ស. ២០២០*



សេចក្ដីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គល
មើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្ដី
ស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មាននៅ
ក្នុងបុគ្គលណា បុគ្គលនោះ មិនមែនជាអ្នកមាន
សីលជាទីស្រឡាញ់ដ៏ក្រៃលែងឡើយ ។